# ការសម្ភាសរបស់អ្នកមីងថៃ ដាលីម

កៈ អ្នកសម្ភាសឈ្មោះ អ៊ុំ ធីដា ខៈ អ្នកត្រូវបានគេសម្ភាស ហៃ ដាលីន

កៈ ជាដំបូងខ្ញុំសូមអរគុណ និង ថ្លែងអំណរគុណដល់អ្នកមីងដែលបានឱ្យខ្ញុំនឹងធ្វើការសម្ភាសអ្នកមីង ហើយការសម្ភាសនេះបានធ្វើឡើងដោយសាកលវិទ្យាល័យ*BYU* ដោយសារតែសាកលវិទ្យាល័យ នឹងចង់ថែរក្សាអំពីជីវប្រវត្តិរបស់ជីដូនជីតារបស់អ្នកមីង។ ហើយក៏ទុកឱ្យកូនចៅជំនាន់ក្រោយនឹង បានមើល ហើយបានដឹងអំពីប្រវិត្តរបស់ជីដូនជីតារបស់អ្នកមីង នៅពេលដែលខ្ញុំនឹងធ្វើការ សម្ភាសអ្នកមីងរួចហើយខ្ញុំសុំដាក់ការសម្ភាសមួយហ្នឹងនៅក្នុងវេបសាយមួយដែលមាន ឈ្មោះថា www.cambodianoralhistories.byu.edu ហើយខ្ញុំជាអ្នកដែលសម្ភាសមានឈ្មោះថា អ៊ុំ ធីដា ហើយ បានធ្វើការសម្ភាសមួយនេះនៅ ថ្ងៃទី១៧ ខែ០១ ឆ្នាំ២០១៨។ ទីតាំងនៅសង្កាត់ភ្នំពេញថ្មី ខណ្ឌ សែនសុខ។ អញ្ចឹងអ្នកមីងយល់ព្រមឱ្យខ្ញុំ ធ្វើការ សម្ភាសអ្នកមីងដែរឬទេ*?*

ខៈ ចាំស! មីងពេញចិត្តឱ្យក្មួយធ្វើការសម្ភាសមីងនៅអ្វីដែលក្មួយចង់ដឹង និង អ្វីដែលមីងចងចាំបាន មីងនឹងប្រាប់ក្មួយឱ្យទៅក្មួយនៅអ្វីដែលក្មួយចង់បាន។

កៈ ចាំស! អញ្ចឹងអរគុណច្រើនអ្នកមីង។ អញ្ចឹងខ្ញុំសូមសួរសំណួរទៅកាន់អ្នកមីងថា តើអ្នកមីងមាន ឈ្មោះអ្វីដែរអ្នកមីង*?*

ខៈ មីងឈ្មោះថា ហៃ ដាលីន ស្រុក កំណើតរបស់អ្នកមីងគឺនៅឃុំ មេសជ្រៅ ស្រុកស្ទឹងត្រង់ ខេត្ត កំពង់ចាម ហើយបច្ចុប្បន្ននេះមីងមករស់នៅភ្នំពេញនៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនស្រុកនេះតែ ម្តង។

កៈ អញ្ចឹងអ្នកមីងរស់នៅកន្លែងហ្នឹងតែម្តង*?*

ខៈ ចាំស! គឺអ្នកមីងរស់នៅទីកន្លែងនេះ។

កៈ អញ្ចឹងតើអ្នកមីងមានឈ្មោះហៅក្រៅដែរអត់ទេអ្នកមីង*?*

ខៈ ឈ្មោះហៅក្រៅក៏មានដែរ គេហៅឈ្មោះ លីម។

កៈ ចាំស! អញ្ចឹងគេហៅអ្នកមីងថាឈ្មោះលីម។ តើអ្នកមីងមានឈ្មោះហៅក្រៅ កាលនៅពីពេលដែល អ្នកមីងហ្នឹងនៅពីក្មេងដែរអត់អ្នកមីង*?*

ខ៖ ចាំស! អ្នកមីងគឺមានកាលដែលអ្នកមីងនៅពីកុមារភាព ឬក៏នៅពីក្មេងហ្នឹងគេបានហៅអ្នកមីងថា កាលហ្នឹងគេហៅថាស្រីតូចមុខប៉ុន ស្លឹងអំព្រិល អីព្រោះតែពេលហ្នឹងអ្នកមីងស្គមស្តែង ហើយមាន មុខហ្នឹងគឺតូច?

ក៖ អញ្ចឹងបច្ចុប្បន្ននេះអ្នកមីងមានអាយុប៉ុន្មានដែរអើយអ្នកមីង?

ខ៖ ហើយក្នុងខែនេះអ្នកមីងមានអាយុសែនសិបបួនឆ្នាំ។

ក៖ អញ្ចឹងតើអ្នកមីងកើតនៅក្នុងឆ្នាំណាដែរទៅអ្នកមីង?

ខ៖ មីងគឺកើតនៅឆ្នាំ១៩៧៤។

ក៖ អ៎ូ! ឆ្នាំ១៩៧៤ ហើយចឹងដូចជាឆ្នាំជូតឬក៏ឆ្នាំអ្វីទៀតដែលនៅក្នុងឆ្នាំខ្មែរហ្នឹងតើអ្នកមីងកើតនៅក្នុង ឆ្នាំអ្វីដែលអ្នកមីង?

ខ. មីងគឺកើតនៅឆ្នាំថោះ។

ក៖ អញ្ចឹងសម្រាប់ទីកន្លែងកំណើតរបស់អ្នកមីងវិញ តើអ្នកមីងបានកើតនៅកន្លែងណាដូចជាភូមិអីឃុំ ស្រុកខេត្តអីអញ្ចឹងអ្នកមីង?

ខ៖ ទីកន្លែងកំណើតរបស់អ្នកមីងអឺ!កើតនៅភូមិក្បាលអូ ភូមិសរសជ្រៅ ស្រុកស្ទង់ត្រង់ ខេត្តកំពង់ ចាម?

ក៖ ហើយអញ្ចឹងតើអ្នកមីងមានបងប្អូនចំនួនប៉ុន្មានអ្នកដែរទៅអ្នកមីង?

ខ៖ មានបងប្អូនចំនួនបីអ្នក?

ក៖ ហើយចុះអ្នកមីងជាកូនទីប៉ុន្មានដែរអ្នកមីង?

ខ៖ មីងគឺជាកូនបងគេ?

ក៖ អញ្ចឹងអ្នកមីងបងគេ។

ខ៖ ចាំសៗ!

ក៖ អញ្ចឹងតើអ្នកមីងមាននៅចងចាំសាច់រឿងពួកគាត់ដែរទេអ្នកមីង?

ខ៖ ចាំស! អ្នកមីងមាននៅចងចាំខ្លះៗពីកុមារភាព ពេលនោះមីងនៅអាយុត្រឹមតែពីរទៅបីឆ្នាំអីតែ ប៉ុណ្ណោះ អ៎ូ! ឈប់សិប។ ចង់សួរមីងថាមិចវិញ?

កៈ ចង់សួរថាតើអ្នកមីងធ្លាប់មានអ្វីខ្លះជាមួយនឹងពួកគាត់កាលពេលដែលអ្នកមីងហ្នឹងនៅតូចអី អញ្ចឹង?

ខៈ
អញ្ចឹងពេលដែលមីងនៅតូចមីងនៅចាំថាអ្នកមីងធ្លាប់បានមើលប្អូនហើយប្អូនហ្នឹងគឺប្អូនប្រុសដែល មានប្អូននៅ
ជាមួយនឹងចង្កេះហើយអៀវប្អូនដើរលេងរហូតដល់តែប្អូនហ្នឹងគាត់ធ្លាក់បក់ដៃ ហើយម៉ាក់គាត់ខឹងហើយកាត់បានវាយ?

កៈ យាយហើយនិងតា តើមួយណាគាត់ជាអ្នកវាយអ្នកមីងមុន?

ខៈ
គឺអឺប្រហែលជាលោកយាយគាត់វាយមុនហើយហើយលោកយាយគាត់វាយដោយសារតែធ្វើឱ្យប្អូន
និងធ្លាក់បាក់ដៃ។ពេលនោះមីងបានពរប្អូនហើយបានពរប្អូននិងឱ្យធ្លាក់ពីលើដៃហើយបាក់ដៃប្អូន ចឹង។
លោកយាយគាត់ខឹងខ្លាំងគាត់ត្រូវតែវាយដែលមីងជាបងដែលអត់ចេះមើលប្អូន?

កៈ
អញ្ចឹងនៅពេលដែលអ្នកមីងនៅពីក្មេងតើអ្នកមីងចូលចិត្តធ្វើអ្វីខ្លះជាមួយនឹងពួកគាត់ដែលអ្នកមីង?

ខៈ កាលដែលអ្នកមីងនៅពីក្មេងមីងចូលចិត្តលេងផ្ទាត់កៅស៊ូជាមួយនឹងប្អូនហើយអឺ! លេងលក់បាយ ឡុកបាយឡ អឺអញ្ចឹងទៅលេងរបៀបក្មេងស្រីនាំប្អូនលេងតែម្តង។

កៈ ហើយចុះអញ្ចឹងតើពួកគាត់ហ្នឹងរស់នៅកន្លែងណាខ្លះ
ហើយរស់នៅកន្លែងណាខ្លះដែរទៅអ្នកមីង ហើយពួកគាត់ហ្នឹងកំពុងធ្វើអ្វីដែរអ្នកមីង?

ខៈ ចាំស!រាល់ថ្ងៃនេះគឺពួកគាត់ហ្នឹងរស់នៅទីក្រុងភ្នំពេញដែលហើយគាត់កំពុងតែធ្វើការងារនៅក្រុម ហ៊ុនមួយ ហើយពួកគាត់ហ្នឹងក៏មានគ្រួសារអស់ទៅហើយ
ដែលហើយពួកគាត់ហ្នឹងក៏មានកូនមាន អឺអស់ដែរ។

កៈ ចាំស។! អញ្ចឹងតើម្តាយរបស់អ្នកមីងតើគាត់មានឈ្មោះអ្វីដែរទៅអ្នកមីង?

ខៈ ឈន លឹន!

កៈ ហើយចុះលោកតា?

ខ៖  ហើយលោកតាប៉ាកាត់ឈ្មោះថាឃុត ហួត ។

ក៖  ហើយតើពេលនេះតើពួកគាត់ហ្នឹងមានអាយុប៉ុន្មានហើយអ្នកមីង?

ខ៖  លោកប៉ាគាត់បានសម្លាប់ហើយ តែនៅតែលោកយាយជាម្ដាយបង្កើតើហើយគាត់មានអាយុ ៦៨ចូល៦៩ឆ្នាំហើយ។

ក៖  ចឹងតើអ្នកមីងមានចាំថាតើពួកគាត់កើតនៅថ្ងៃខែឆ្នាំណាដែរទេអ្នកមីង? ដូចជាអ្នកមីងមាននៅចាំ ដែរទេអ្នកមីង?

ខ៖  អូ៎!ថ្ងៃខែឆ្នាំកំណើតរបស់លោកតាលោកយាយ មីងអត់ចាំផងហ្នឹងតែដឹងថាគាតើអាយុក្នុងវ័យនេះ គឺមានអាយុ៦៨ឆ្នាំហើយ។

ក៖  អញ្ចឹងដូចជាឆ្នាំច័ន្ទគិតអីគឺជាឆ្នាំជូតឆ្នាំថោះអីអញ្ចឹង តើមីងមានដឹងថាពួកគាត់ហ្នឹងកើតនៅឆ្នាំអីដែរទេ? អ្នកមីងឬឆ្នាំមួយណាដែរទៅអ្នកមីង?

ខ៖  លោកយាយគាត់គឺកើតនៅឆ្នំាថោះអីហ្នឹងដែរហ្នឹង?

ក៖  ហើយចុះលោកតាវិញ?

ខ៖  អត់ដឹងថាគាត់ កើតនៅឆ្នាំហ្នឹងអីទេអត់បានសួរប៉ាថាគាត់កើតឆ្នាំអីផងហ្នឹងនិយាយរួមទៅដឹងក៏ ប៉ុន្តែគឺភ្លេចតាងពីប៉ាគាត់បានស្លាប់ទៅ។

ក៖ អញ្ចឹងតើអ្នកមីងមានដឹងថាពួកគាត់ហ្នឹងកើតនៅកន្លែងណាដែលអត់អ្នកមីងដូចជានៅស្រុកណាអី អញ្ចឹងអ្នកមីង?

ខ៖  សម្រាប់លោកតាយាយពួកគាត់កើតនៅភូមិក្បាលអូ ឃុំ មេស ជ្រៅ ស្រុងស្នង់ត្រង់ជាមួយនឹងអ្នក មីងដែរ? ហើយលោកតាវិញដូចជាភូមិកកើតរបស់លោកតាវិញមីងអត់សួរចងចាំអីនោះទេ ធ្លាប់ ឬកគាត់និយាយការដែលគាត់នៅរស់ គឺនៅអូរាំងឪ តែដូចជាអត់ស្គាល់ភូមិឃុំអីទេ តែដឹងថានៅ អូរាំងឪ។

ក៖  ចា៎ស! អរគុណអ្នកមីងអ្នកអញ្ចឹង តើឪពុករបស់អ្នកមីង តើគាត់ប្រកបរបរអ្វីមកចិញ្ចឹមជីវិតដែរទៅ អ្នកមីង?

ខ៖  កាលហ្នឹងឪពុករបស់មីងគាត់បានប្រកបរបររបស់គាត់ គឺលោកខោអាវជជូសតាងពីអើយមកម្ល៉េះ

នោះជាអាជីពអ្នកខ្ញុំបានដឹងពីគាត់នៅពេលដែលខ្ញុំធំដឹងក្ដីមកហើយអាជីពដែលខ្ញុំអត់ទាន់ដឹងក្ដី មកគឺគាត់ជាជាងប៉ះកង់។

ក៖ ហើយអញ្ចឹង តើគាត់ជាមនុស្សយ៉ាងមិចដែរអ្នកមីង?

ខ៖ គាត់ជាមនុស្សស្លូតត្រង់។

ក៖ ហើយចុះម៉ាក់យាយអ្វីអ្នកមីងតើគាត់ធ្លាប់ធ្វើអ្វីសម្រាប់ចិញ្ចឹមជីវិតដែរអ្នកមីង?

ខ៖

ម្ដាយមីងគឺលោកយាយគាត់បានលក់អីវ៉ាន់នៅក្នុងផ្សារអីជាអីវ៉ាន់បន្តិចបន្តួចនៅក្នុងផ្សារ គឺបន្តិចបន្តួច បំផុតនៅក្នុងផ្សារដើម្បីគាត់អាចចិញ្ចឹមជីវិតរបស់គាត់។

ក៖ តើគាត់ជាមនុស្សបែបណាដែរទៅអ្នកមីង?

ខ៖ គឺមនុស្សគាត់គឺ ស្លូតបូត ស្មោះត្រង់
ហើយគាត់ជាមនុស្សដែលនិយាយអ្វីដែលជាពិតប្រាកដ។

ក៖

អញ្ចឹងតើអ្នកមីងមានចង់ចាំអ្វីខ្លះដែលទាក់ទងជាមួយនឹងឪពុកម្ដាយរបស់អ្នកមីងខ្លះដែរទេអ្នក មីង?

ខ៖ ចាស! នៅចងចាំខ្លះដែរទេអ្នកមីងទាក់ទងជាមួយនឹងសាច់រឿងឪពុកម្ដាយ
គឺតាមងពីមីងដឹង ក្ដី ឃើញពួកគាត់ហ្នឹង
មមាញឹកក្នុងការងារដូចជាប្រកបរបរដើម្បើចិញ្ចឹមកូនហើយ គាត់ក៏បានធ្វើ ស្រែ និង ចម្ការគឺខ្ញុំហ្នឹងនៅចងចាំទាំងអស់ហើយ។ ថ្ងៃដំបូងដែលខ្ញុំនឹង ធ្វើចម្ការជាមួយនឹង លោកប៉ា ហើយពេលដែលខ្ញុំបានទៅស្រែជាមួយនឹងអ្នកម៉ាក់អឺ!លោកយាយគឺខ្ញុំនៅចងចាំបាន ច្រើន។

ក៖ ចាស! អញ្ចឹងតើពួកគាត់ធ្លាប់ដែលបាននិយាយអំពីប្រវិត្តរបស់ពួកគាត់
ប្រាប់អ្នកមីងដែរទេ? កាល ដែលអ្នកមីងនៅតូចៗអីអញ្ចឹង។

ខ៖ ចាស! ពួកគាត់ធ្លាប់និយាយពេលដែលអត់ឃ្លានពីកាលដែលគាត់បានឆ្លងកាត់កាលពេលសម័យ ប៉ុល ពត គឺគាត់បានឆ្លងកាត់ច្រើន ហើយពេលដែលគាត់នៅសម័យ ប៉ុល ពត ហ្នឹងគឺគាត់បាន ឆ្លងកាត់ច្រើន។ ពួកគាត់បានទៅរែកដីរែកអីហ្នឹង ធ្វើជីអាចម៍គោ ដកស្ទូង ធ្វើសំណាប ហើយពួកវា សុទ្ធតែជារឿងដែលពិបាក
ហើយមួយទៀតគាត់បានថាជំនាន់ ប៉ុល ពតគឺមានការអត់ឃ្លាអីអញ្ចឹង ទៀត។

ហើយកាលអត់ឃ្លាហ្នឹង គឺខ្លាំងមែនទែន ស្ទើរដែលអត់ក្រពះ និង គ្មានជីវិតពេលដែលអត់ឃ្លាត និង
គ្មានចំនីអាហារអីហ្នឹងមកហើយ។នៅជំនាន់នោះគាត់បាននិយាយប្រាប់ថាចែករបរ របប។ ចាំស! គឺគេចែកឱ្យតែមួយម្នាក់មួយវែកទេ តែរបបទាំងនោះគឺគាត់អត់បានយកទៅញុំាខ្លួនគាត់នោះទេ។គាត់សុទ្ធចិត្តយកមកទុកឱ្យ កូនហើយមានការឈឺចាប់ច្រើនទៀត ដែលគាត់បាន និយាយហើយ។ ខ្ញុំអឺ!កាលបានភ្លេចខ្លះៗ ហើយក៏បានចងចាំខ្លះដែលកាលហ្នឹងពេលដែលខ្ញុំមាន អាយុជាបីឆ្នាំគេបានយកខ្ញុំទៅដាក់នៅកន្លែងកុមារ គឺនៅកន្លែងដែលមានពួកចាស់ៗ ដែលមើល កុមារហ្នឹង គឺខ្ញុំនៅស្នាក់នៅហ្នឹងហើយម្ដាយគាត់ទៅវែកអាចម៍គោ ទៅវែកសំណាបជ្រោកស្រូវអី។អញ្ចឹងដល់ពេលដែលល្ងាចឡើង បានមកយកកូនបានមកយកខ្ញុំនឹងចេញពីកន្លែងកុមារ មកយក ផ្ទះទាំងអស់គ្នា ហើយព្រឹកឡើងគាត់បានងើបទៅវិញទៀត  ចង់ការជួបជុំជាមួយនឹងឪពុកម្ដាយ និង កូនគឺមិនដែលបានជួបជុំជាលក្ខណៈបានឃើញគ្នានោះទេ ពីមុខមាត់ឱ្យច្បាស់នោះទេ។ ម៉ែកូនហើយនិងឪពុកម្ដាយ  គឺបែកគ្នារហូត។ វាមានការពិបាកនៅពេលដែលឮថាគាត់បាន និយាយរឿងទាំងអស់នោះ  គឺមិនអាចឱ្យខ្ញុំនឹងទប់ទឹកម្ដាយ ដែលអាណិតម្ដាយនៅពេលដែលនឹង ថាគាត់បានឆ្លងកាត់រឿងជាច្រើនជំនាន់តាំងពីសម័យ ប៉ុល ពត។

ក៖	ចាំស! អញ្ចឹងតើអ្នកមីងមានចាំឈ្មោះរបស់ជីដូនជីតារបស់អ្នកមីងដែរអត់អ្នកមីង?

ខ៖	ជីដូនជីតារបស់មីង គឺមានឈ្មោះអឺ!ខាងលោកយាយមានឈ្មោះថា ឈន ប៉ៃ មួយទៀតមាន ឈ្មោះថា ឈន សុខ។

ក៖	ហើយចុះខាងឪពុកវិញអ្នកមីង?

ខ៖	ខាងលោកប៉ាវិញគាត់មានឈ្មោះថា តា យុត។

ក៖	ហ្នឹងយាយខឹម ។

ខ៖	ហ្នឹងហើយគឺហ្នឹងយាយខប់។ ហ្នឹងដូចជាយាយយាយខឹមតាហើយដូចជាចង់ភ្លេច។

ក៖	ហ្នឹងហើយគាត់ជាយាយតួចរបស់ខ្ញុំ។

ខ៖	(ពួកយើងបានសើច) ចង់ភ្លេចលោកយាយ។

ក៖	អញ្ចឹងតើពួកគាត់ហ្នឹងកើតនៅឆ្នាំខែថ្ងៃណាដែរទៅអ្នកមីង អ្នកមីងមាននៅចាំទេ?

ខ៖ អឺ! ដូចជាអត់ចាំអីនោះទេ។

ក៖ អញ្ចឹងតើអ្នកមីងមានដឹងថា តើពួកគាត់ហ្នឹងបានកើតនៅស្រុកណាអីអញ្ចឹងហើយ តើពួកគាត់ហ្នឹងមក ពីអ្នកខេត្តណាអីអញ្ចឹង?

ខ៖ បើនៅខាងលោកយាយវិញដូចជាលោកតាហ្នឹង គាត់នៅខាងជ្រួយស្ទែងក្របីដែល គេហៅថាតា ក្របាមកជ្រួយស្ទែងក្របីលើខេត្តក្រចេះ តែបើខាងលោកយាយប៉ែវិញ គាត់នៅភូមិមេជ្រៅស ស្រុកស្ទឹងត្រងនេះតែម្តង ហើយបើខាងលោកប៉ានោះវិញ ដូចជាអត់សូវបានចាំដែលព្រះថាយាយ ទូច យើងដែលជាអត់សូវបានចាំដែរហ្នឹង យូរទៅវាងភ្លេចដូចជានៅចុងៗមាត់។

ក៖ អញ្ចឹង តើគាត់នៅខេត្តអីគេដែរអ្នកមីង?

ខ៖ ហ្នឹងគឺនៅតាកែវ។

ក៖ ចុះតាទូតវិញ?

ខ៖ ហ្នឹងតាទូចគាត់នៅអូរាំងឪ។

ក៖ ចាំស! អញ្ចឹងអ្នកមីងរស់នៅស្រុកកំណើតរបស់អ្នកមីង ហ្នឹងអស់រយៈពេលប៉ុន្មានឆ្នាំហើយទើប អ្នកមីងបានបន្ទាប់មករស់នៅភ្នំពេញវិញ?

ខ៖ មីងរស់នៅស្រុកកំណើតរបស់ខ្លួនឯងហ្នឹងបានត្រឹមអាយុដប់ពីរឆ្នាំ បានផ្លាស់ទីលំនៅហ្នឹង មកនៅ ភ្នំពេញវិញតាំងពីអាយុដប់ពីរឆ្នាំមកម្លេះ ហើយមកនៅក្នុងទីក្រុងភ្នំពេញហ្នឹងរហូតមកដល់សព្វថ្ងៃហ្នឹង។

ក៖ ចាំស! អញ្ចឹងតើអ្នកមីងមានបងប្អូនឬក៏សាច់ញាតិដែលគាត់ធ្លាប់រស់នៅឯក្រៅប្រទេសដែរទេអ្នកមីង?

ខ៖ ចាំស! អត់មានទេ។

ក៖ អត់ទាំងអស់តែម្តងមែនអ្នកមីង។

ខ៖ ចាំស! អត់មានទេ។

ក៖ ចាំស! តើប្តីរបស់អ្នកមីងតើគាត់មានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ ប្តីរបស់អ្នកមីងគឺមានឈ្មោះថា ទោង សារ៉ាត ហើយរាល់ថ្ងៃនេះគាត់ ហើយនិង មីងបានចែកផ្លូវ ហ្នឹងគ្នាហើយ។

កៈ ចា៎ស! ខ្ញុំសុំទោសអ្នកមីង ហើយចឹងអាពាហ៍ពិពាហ៍របស់អ្នកមីង តើរាប់នៅឆ្នាំណាខែណាទៅអ្នក មីង?

ខៈ មីងបានរៀបអាពាពិហ៍ពាហ៍នៅឆ្នាំ១៩៩៨ ហើយមកដល់ឆ្នាំពី២០០០ និង ឆ្នាំ២០០៥។ មីងបាន ចែកផ្លូវគ្នាជាមួយនឹងស្វាមី ចង់រស់នៅជាមួយនឹងស្វាមីអស់រយៈពេលប្រាំពីរឆ្នាំ។

កៈ ចា៎ស! អញ្ចឹងចំពោះអាពាហ៍ពិពាហ៍របស់អ្នកមីងវីញ តើអ្នកមីងមានការហ្នឹងដោយខ្លួនឯង ឬក៏ ចាស់ពួកគាត់នាំឱ្យស្គាល់គ្នាដែរអ្នកមីង?

ខៈ ស្វាមីរបស់អ្នកមីងនេះគឺរៀបការហ្នឹង មិនមែនដោយសារតែស្រឡាញ់គ្នានោះទេ គឺដោយសារតែ ចាស់ទុំ និង សាច់ញាតិ។

កៈ អញ្ចឹងពួកគាត់ជាអ្នកសុំផ្ដុំឱ្យអ្នកមីងមែនអត់អ្នកមីង។

ខៈ ចា៎ស!

កៈ អញ្ចឹងតើមានថ្លៃជំនូនដែរទេអ្នកមីង?

ខៈ មានថ្លៃជំនូនហើយថ្លៃជំនូននៅឆ្នាំ១៩៩៨ហ្នឹង គឺ បានបីពាន់។

កៈ បីពាន់រៀល។

ខៈ ទេបីពាន់ដុល្លារ។

កៈ អូ៎! វាច្រើនដែរអ្នកមីង។

ខៈ ចា៎សៗ!

កៈ ហើយចុះអ្នកមីងចេះអាន និង ចេះភាសាខ្មែរហ្នឹងបានល្អដែរទេអ្នកមីង*?*

ខៈ បានមួយមធ្យម។

កៈ ហើយចឹង តើអ្នកមីងមានចេះភាសាផ្សេងទៀតដែរទេអ្នកមីង? ដូចជាចិន អង់គ្លេស អីអញ្ចឹងអ្នក មីង*?*

ខៈ មីងអត់ចេះទេ ចេះតែខ្មែរទេ។

កៈ តែខ្ញុំឃើញមីងអាចវាយកុំព្យូទ័របាន។

ខៈ ចេះអស់គ្លេសបានតិចតួច។

ក៖	ហ្នឹង! អង់គ្លេស ខ្ញុំគាត់ចេះហើយបាននិយាយជាមួយនឹងខ្ញុំដែរ។ ចឹងតើអ្នកមីងបានរៀនភាសាខ្មែរហ្នឹងបានត្រឹមថ្នាក់ទីប៉ុន្មានដែរអ្នកមីង?

ខ៖	មីងរៀនអក្សរខ្មែរបានត្រឹមកម្រិតថ្នាក់ទី១២ ។

ក៖	អញ្ចឹងវាចូលវិទ្យាល័យ តើអ្នកមីងរៀននៅសាលាណាដែរអ្នកមីង?

ខ៖	មីងរៀននៅសាលាបាក់ទូក។

ក៖	ចាស! អញ្ចឹងតើអ្នកមីងធ្លាប់មានមិត្តភក្តិស្និតស្នាលដែលធំធាត់មកជាមួយនឹងគ្នាដែរទេអ្នកមីង?

ខ៖	ធ្លាប់មាន! មានមិត្តភក្តិដែលធ្លាប់មានពីរទៅបីនាក់ ដែលការពីសម័យនៅរៀនជាមួយនឹងពួកគាត់។

ក៖	ហើយចឹងអ្នកមីងនៅតែបន្តរាប់អានគ្នា។

ខ៖	ចាស! តាំងពីក្មេងដែលពួកយើងនៅពីកុមារភាពមកដល់សម័យនេះ ពួកយើងនៅតែរាប់អានគ្នាអី អញ្ចឹងដដែរហ្នឹង។

ក៖	ប៉ុន្តែពួកគាត់មានគ្រួសារហើយអស់ហើយនំ។

ខ៖	ពួកគាត់មានគ្រួសារអីហ្នឹង អស់ហើយហ្នឹង ហើយមានចៅអស់ទាំងផង។

ក៖	អូ! អញ្ចឹងនៅតែអ្នកមីងដែលអត់ទាន់មានចៅ។

ខ៖	ចាស! នៅតែមីងអត់ទាន់មានដោយសារតែមីងកូនសុទ្ធតែប្រុស។

ក៖	ចុះតើពួកគាត់មានឈ្មោះអ្វីដែរទៅអ្នកមីងមិត្តភក្តិរបស់អ្នកមីង?

ខ៖	ពួកគាត់ហ្នឹងមានឈ្មោះថាអឺ! សុខ ទេវីន ភារុម មនីនែត ហើយនិង ថាវីមួយទៀត។

ក៖	ចាស! អរគុណអ្នកមីង ចឹងចង់សួរអ្នកមីងមួយទៀតពេលដែលអ្នកមីងមានទំនាក់ទំនងជាមួយនឹង ដូចជាធ្លាប់សិក្សាជាមួយគ្នានឹងរឿងអីអញ្ចឹង?

ខ៖	នៅចងចាំទាំងអស់ ព្រោះពេលដែលមីងនៅពីក្មេងនៅវ័យសិក្សា។ មីងចូលចិត្តលេងគប់ លេង ឈូស  លេងលោត កៅស៊ូជាមួយនឹងមិត្តភក្តិទាំងហ្នឹង។ ហើយពេលដែលលេងហើយហ្នឹង។ អញ្ចឹងទៅពេលខ្លះហ្នឹងក៏ឈ្លោះគ្នាអីអញ្ចឹង ទៅពេលខ្លះក៏និយាយរកគ្នាវិញ។ អញ្ចឹងទៅហើយអ្វី ដែលសំខាន់ អញ្ចឹងទៅមិញចូលចិត្តដាំសួននៅសាលា។

កៈ	អញ្ចឹងអស់ហើយន៎អ្នកមីងមានតែ ប៉ុន្ណេទេន៎អ្នកមីង?

ខៈ	ចា៎សៗ! មីងមានតែប៉ុណ្ណឹងទេ។

កៈ	ចា៎ស! អញ្ចឹងតើអ្នកមីងមានដែលធ្វើការនៅវាលស្រែដែរទេអ្នកមីង?

ខៈ	ធ្លាប់ស្ទឹងស្រែដកស្រូវអីហ្នឹងគឺធ្លាប់ៗទាំងអស់។

កៈ	ចុះអាជីវកម្មជាអ្នកគ្រួសារអី តើអ្នកមីងធ្លាប់បានធ្វើវាទេ?

ខៈ	អាជីវកម្មសម្រាប់គ្រួសារធ្លាប់មានគឺលក់ដូរនៅផ្សារលក់ នៅក្នុងផ្សារអូឬស្សី ក្នុងផ្សារដេពូលកន្លងមកដែលមីងបានរៀនផងហើយក៏លក់ដូរផងដែរ។

កៈ	ចុះតើអ្នកមីងធ្លាប់បានធ្វើការងារអ្វីខ្លះ សម្រាប់ការងារដូចជាធ្លាប់ឆ្លងកាត់ការងារអ្វីខ្លះអី អញ្ចឹងអ្នក មីង?

ខៈ ធ្លាប់ឆ្លងកាត់ការងារច្រើនតែគ្រាន់ថា បើឱ្យនិយាយអំពីរឿងការងារមិនធ្លាប់ធ្វើពីក្រុមហ៊ុនមួយទៅ ក្រុមហ៊ុនមួយទៀតអីអញ្ចឹង ហើយរហូតមកដល់ពេលបច្ចុប្បន្ននេះមីងធ្វើតែការងារវិទ្យុនោះទេ។

កៈ	ចា៎ស! អញ្ចឹងតើជីវិតរបស់អ្នកមីងហ្នឹងពេលឥឡូវនេះ តើជីវិតរបស់អ្នកមីងហ្នឹងមានការផ្លាស់ប្ដូរអ្វី ខ្លះ ដែរទៅអ្នកមីង?

ខៈ	គឺជីវិតរបស់អ្នកមីង គឺមានការតស៊ូច្រើនពេលដែល មិនមករស់នៅក្នុងក្រុងភ្នំពេញហ្នឹងអី! សូម និយាយ បកទៅក្រោយបន្តិចទៅអញ្ចឹង។ អញ្ចឹងនៅពេលដែលយើងមករស់នៅក្នុងទីក្រុងភ្នំពេញ យើងត្រូវតែរកលុយ ដើម្បីរៀនខ្លួនឯងព្រោះតែយើងហ្នឹង គឺគ្មានឪពុកម្ដាយណាផ្គួចផ្ដើម។ យើង ព្រោះមកនៅភ្នំពេញគឺមកនៅជាមួយហ្នឹងជីដូន ហើយលោកយាយ និង លោកតាគឺនៅស្រុកកំណើតអញ្ចឹង ធ្វើឱ្យមីងពិបាកក្នុងការតស៊ូចិញ្ចឹមជីវិតខ្លួនឯង និង ការរៀនសូត្ររបស់ខ្លួនឯង។

កៈ	អញ្ចឹងតើអ្នកមីងធ្លាប់មានម្ហូបអ្វី និង ល្បែងអីដែលអ្នកមីងហ្នឹងចូលចិត្តអីអញ្ចឹងអ្នកមីង?

ខៈ	ម្ហូបដែលអ្នកមីងចូលចិត្តគឺសម្លម្ជូរដែលជារបៀបយើងជាអ្នកស្រែ។

កៈ	ចុះសម្រាប់ល្បែងប្រជាប្រិយវិញអ្នកមីង?

ខ៖  ចំពោះល្បែងប្រជាប្រិយវិញ ចូលចិត្តលេងទាញព្រ័ត្រហើយលែងបោះឈូង និង ចូលចិត្តលេងទាញ ខ្សែអាដឹងដូចជាហៅអី។

ក៖     ទាញព្រ័ត្រ។

ខ៖     ពេលគេលេងរត់ខ្សែហ្នឹង គឺគេលេងសម័យ គេហៅថាលេងរត់មុខប្រាំ។

ក៖     លេងមួយកម្មពីរកម្មមែន។

ខ៖     ចាស! ហ្នឹងហើយ។

ក៖     ចុះ តើអ្នកមីងមាននៅចាំចម្រៀងណាមួយ ដែលអ្នកមីងគិតថា នៅចាំតាំងពីក្មេងរហូតមកដឹងពេល នេះ ដែលទេអ្នកមីងដូចជាអ្នកធ្លាប់ច្រៀង និង ធ្លាប់ចាំរហូតមកដល់ពេលនេះដែរទេអ្នកមីង?

ខ៖     ចូលចិត្តលោកតា ស៊ុន ស៊ីសាមុត ហើយបទមួយទៀតភ្លេងចំណាងជើង តែពេលដែលចាក់យើង អាចនៅចាំវាបានខ្លះដែលហើយនៅបទមួយទៀតរបស់លោកកែវសារ៉ាត គឺបទរសៀលគងព្រៃ។

ក៖     អ្នកមីងចំលែកចូលចិត្តតែបទប្រុស។

ខ៖     ចូលចិត្តបទប្រុស។ ព្រោះបទស្រីអត់សូវចូលចិត្ត។

ក៖     ចាស! អរគុណអ្នកនិយាយចឹង តើនៅក្នុងគ្រួសាររបស់អ្នកមីង តើពួកគាត់ហ្នឹងធ្លាប់មានអ្នកណា គេចេះលេងឧបរកណ៍ដែរទេអ្នកមីង?

ខ៖     នៅក្នុងគ្រួសារបស់មីងហ្នឹង គឺមានមួយដែលគាត់ចូលចិត្តលេងឧបរកណ៍ ភ្លេងផ្នែកខាងហ្គីតា ហើយគាត់ចង់ខ្លាងមែនទែនទាំងពីរទាំងប្រុសបីនាក់។

ក៖     ពួកគាត់មានឈ្មោះអ្វីដែរអ្នកមីង?

ខ៖     បើកូនប្រុសអ្នកមីងបងគេហ្នឹង គាត់មានឈ្មោះថា នុត ឆាវ៉ាន់។ ទីពីរឈ្មោះថា នុត ហៃ លឹម ដែនទ័រ នុត សាយុទ្ធ។ ពួកគាត់សុទ្ធតែជាអ្នកដែលចូលចិត្តនៅឧបរកណ៍ភ្លេង។

ក៖     ចុះ តើផ្ទះរបស់អ្នកមីងហ្នឹងមានលក្ខណៈយ៉ាងមិចដែរ? អ្នកមីងតាំងពី នៅក្មេងរហូតមកដល់ ពេលនេះអ្នកមីង?

ខ៖     ផ្ទះរបស់អ្នកមីង គឺជាផ្ទះដែលតូចល្មមរស់នៅតាមលក្ខណៈគ្រួសារមួយមធ្យម។

ក៖     ជាផ្ទះថ្មត្រូវទេអ្នកមីង។

ខ៖ ផ្ទះយើងហ្នឹង គឺខាងក្រោយហើយខាងលើគឺឈើ។

ក៖ ចឹង
តើផ្ទះដែលអ្នកមីងសាងសង់ដោយខ្លួនអ្នកមីងផ្ទាល់ឬក៏អ្នកមីងជួលគេដែរអ្នកមីង?

ខ៖ សម្រាប់ផ្ទះនេះ គឺមីងជួលគេទាំងស្រុង តែម្តងឱ្យគេ
ហ្នឹងធ្វើឱ្យមីងគ្រាន់តែរកថវិកាសម្រាប់ផ្តល់ឱ្យគេហ្នឹងជួយធ្វើ។

ក៖ ចាំស! ណាមួយអ្នកមីងជា មនុស្សមិនមានកម្លាំងណាទៅនេះទេ។ ចាំស!
អញ្ចឹងអរគុណអ្នកមីង ច្រើនហើយ
តើអ្នកមីងបានប្រើប្រាស់សម្ភារៈអ្វីខ្លះសម្រាប់សាងសង់ផ្ទះមួយនេះដែរទៅអ្នកមីង?

ខ៖ អឺ! ប្រើប្រាស់អ្វីខ្លះ?

ក៖ ចាំសៗ!

ខ៖ ការប្រើប្រាស់គឺមានដែន និង មានឈើ មានស៊ីម៉ង់ មានឥដ្ឋតែប៉ុណ្ណឹង។

ក៖ ចាំសៗ! តើអ្នកមីងមានបន្តជំនាញអីដែរបន្តមកពីគ្រួសារតាំងពីមុនមកដូចជាវេញ
ខ្សែ ឬក៏ ជំនាញ ខាងធ្វើស្ករត្នោតអីអញ្ចឹអ្នកមីង?

ខ៖ ជំនាញខាងធ្វើស្ករត្នោតមីងក៏ចេះដែរ ព្រោះអីតាំងពីក្មេងមកអីអញ្ចឹង
ធ្លាប់បានឃើញចាស់ គាត់ ទៅរំងាស់ត្នោតហ្នឹងទៅជាស្ករ
ទៅឈរមើលអញ្ចឹងក៏ចង់នៅជំនាញ ទាំងនេះរំងាស់ស្ករហ្នឹងឱ្យទៅ ជារាងនេះអញ្ចឹង
វាស្ងួតទៅក្លាយជាស្ករត្នោតហើយ។

ក៖ អញ្ចឹង តើអ្នកមីងអាចប្រាប់ខ្ញុំពីពេលដែលលំបាកបានទេអ្នកមីង?

ខ៖ ជីវិតលំបាកគឺវាពេលដែលលំបាកហ្នឹងគឺ វាលំបាកពេកទៅហើយហ្នឹង។
ចាំស!គឺពិបាកច្រើនមែន ទែន តែម្តងក្នុងការចិញ្ចឹមកូនតែម្នាក់ឯង បម្រើកូន
ដូចជាការបោកគក់ សំលៀបបំពាក់ឱ្យពួក គាត់ការជំាបាយធ្វើម្ហូបឱ្យពួកគាត់។
ការរកលុយឱ្យកូនរៀន គឺវាពិបាកមែនទែន ដោយសារតែមីង ជាមនុស្សតែម្នាក់ឯង
ប្រុសក៏មីងមនុស្សក៏ជាមីង ការងារក្នុងក្រៅគឺតែមីង តែម្នាក់ឯង គឺកូនបាន ត្រឹមតែមួយរៀន
គាត់អត់ទាន់អាចជួយអីយើងបានទេគឺពួកគាត់នៅក្នុងវ័យសិក្សា។

ក៖ តើអ្នកមីងអាចឆ្លងកាត់ការលំបាកហ្នឹងយ៉ាងដូចម្តេចដែរអ្នកមីង?

ខ៖ ការឆ្លងកាត់ដូចជាការអត់លុយ
អត់មានលុយឱ្យកូនទៅរៀនមានឬក៏អត់លុយខ្លួនឯង ប៉ុន្តែទោះជា

យើងណាក៏មីងនៅតែតស៊ូដែលទោះជាអត់មានមធ្យាបាយធ្វើដំណើរក៏មីងនៅតែដើរថ្មើរជើងបានដែលដើម្បីរកប្រាក់កម្រៃទាំងអស់នោះទុកឱ្យកូនហ្នឹងរៀន។

ក៖ អ្នកមីងជាមនុស្សអ្នកដែលជំនះបានគ្រប់ឧបសគ្គ ដើម្បីស្វែងរកលុយ ដើម្បីផ្គត់ផ្គង់សម្រាប់ កូនអ្នក មីងរៀន។

ខ៖ និយាយរួចទៅគឺយើងបញ្ចេញកម្លាំងកាយ និង កម្លាំងចិត្តហ្នឹង គឺដើម្បីឱ្យកូនហ្នឹងរៀនមិនរារែកកូនតែ កូនមានចំនេះដឹង។

ក៖ ចា៎ស! ចុះអញ្ចឹងតើអ្នកមីងធ្លាប់មានបទពិសោធន៍ល្អយ៉ាងមិចដែរអ្នកមីង?

ខ៖ ចំនុចល្អៗទីមួយ ខំប្រឹងធ្វើការងារចង់ឱ្យកូនៗរបស់មីង គឺមើលឃើញពីទឹកចិត្តរបស់មីងដោយ ផ្ទាល់តែម្តង និង ឱ្យកូនមានការព្យាយាមដូចជាមីងអញ្ចឹងដែរ។

ក៖ អញ្ចឹង តើពេលដែលអ្នកមីងនៅពីក្មេង តើអ្នកមីងធ្លាប់គិតថាអ្នកមីងនឹងចង់ធ្វើអ្វីដែរ?ហើយមាន សេចក្តីសង្ឃឹមថាចង់ធ្វើអ្វីពេលដែលអ្នកមីងធំឡើង?

ខ៖ ថាថ្ងៃណាមួយមីងនឹងមានផ្ទះខ្លួនឯង មីងនឹងមានកន្លែងរកស៊ីលក់ដូរ លក់ឥវ៉ាន់នៅក្នុងផ្ទះ ប៉ុន្តែ ពេលនេះគឺមីងអត់ទាន់មានឥវ៉ាន់លក់នៅក្នុងផ្ទះនៅឡើយទេទើបតែមានតែផ្ទះទេ។

ក៖ អញ្ចឹង បើអ្នកមីងមានអ្វីចង់ប្រាប់ផ្ញើរទៅកាន់ពួកគាត់ តើអ្នកមីងចង់ផ្តាំអ្វីខ្លះ ទៅកាន់ពួកគាត់អី អញ្ចឹងអ្នកមីង?

ខ៖ មីងចង់ផ្តាំទៅកូនៗក៏ដូចជាក្មួយៗឱ្យកូនចេះយល់ដឹងអាចពីពេលវេលា ដែលយើងបានតស៊ូទាំង អស់។ ចា៎ស! គឺទីមួយ គឺយើងត្រូវអត់ធ្មត់ក្នុងការរកកម្រៃ សម្រាប់ចិញ្ចឹមជីវិត។ ហើយទីពីរគឺត្រូវ យល់ដឹងក្នុងការយកចំនេះដឹង ដើម្បីចិញ្ចឹមជីវិតរបស់យើងទៅថ្ងៃក្រោយអញ្ចឹងទៀត កុំឱ្យមានការ លំបាក ដូចជាអ្នកមីងព្រោះមីងបានឆ្លងការលំបាកជាច្រើន នៅពេលដែលមីងសិក្សា ហើយមិត្ត បានតទៅមហាវិទ្យាល័យ។ អញ្ចឹងមីងមានការពិបាកយ៉ាងខ្លាំង ដូចជាសព្វថ្ងៃហ្នឹង បើយើងអត់ មានជំនះដឹងអត់ បានធ្វើការងារធំដុំអីទេ ហើយយើងរកកម្រៃហ្នឹង ក៏បានតិចដែរ។ អញ្ចឹងក៏ចង់ឱ្យក្មួយៗ ប្អូនៗកូនៗជំនាន់ក្រោយហ្នឹងមានការងារធ្វើ ហើយយល់ដឹងជាមួយនឹងការរៀនសូត្រ និង ការគ្រេបជញ្ជក់យកចំនេះដឹង ច្រើនដូចជាគេហ្នឹងថាទំពាំងស្នងឬស្សី

លុះត្រាតែយើងហ្នឹងរឹងមាំងខ្លួនឯងដែរអញ្ចឹងចង់ឱ្យកូនៗ និង
ក្មួយទាំងអស់ហ្នឹងខំសិក្សានៅផ្លូវដែរល្អ។

កៈ អញ្ចឹង ខ្ញុំសូមអរគុណដល់អ្នកមីង
ហើយខ្ញុំសូមដាក់ការសម្ភាសមួយនេះទៅក្នុងវេបផ្សាយមួយហ្នឹងហើយ
ក៏សូមថតរូបអ្នកមីងផងដែរ បានអត់អ្នកមីង?

ខៈ ចាំស! បានកូនបានថតទៅ។

កៈ ចាំស! អរគុណច្រើនអ្នកមីងសម្រាប់ការសម្ភាស និង
ការចំណាយពេលវេលាដែលមានតម្លៃរបស់ អ្នកមីង
ដើម្បីក្មួយអាចធ្វើការសម្ភាសអ្នកមីង។ ចាំស! អរគុណច្រើនអ្នកមីង ជម្រាបលាអ្នកមីង។

ខៈ ចាំស! កូនជម្រាបលា។

កៈ ចាំស!